ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងអភិវឌ្ឍន៍ជនបទ

# ទិន្នន័យសារពើភ័ណ្ឌផ្លូវជនបទខេត្តស្ទឹងត្រែង




## បោះពុម្ពលើកទី ២

## ខែ សីហា ឆ្នាំ ២០២០

# បុព្វកថា

ការអភិវឌ្ឍប្រទេសជាតិ ក្រោមការដឹកនាំប្រកបដោយគតិបណ្ឌិត និងចក្ខុវិស័យវែងឆ្ងាយរបស់ **សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា** បានកំណត់យកវិស័យអាទិភាពបួនគឺ **ផ្លូវ ទឹក ភ្លើង** និងមនុស្ស។ ចាប់ពីនីតិកាលទី ៦ មកអាទិភាពទាំងបួនត្រូវបានផ្លាស់ប្តូរលំដាប់នៃសារៈសំខាន់ទៅជា **មនុស្ស ផ្លូវ ភ្លើង** និង**ទឹក** ដើម្បីផ្តល់អាទិភាពទីមួយទៅលើមនុស្ស និងនៅតែបន្តផ្តោតការយកចិត្តទុកដាក់ទៅលើ **ផ្លូវ ភ្លើង** និង**ទឹក**ដដែល ក្នុងយុទ្ធសាស្ត្របន្តជំរុញការអភិវឌ្ឍសេដ្ឋកិច្ច និងសង្គមកិច្ច ស្របទៅតាមដំណាក់កាល និងស្ថានភាពជាក់ស្តែង ដែលបាននិងកំពុងធ្វើឱ្យសេដ្ឋកិច្ចមានកំណើនខ្ពស់ប្រកបដោយចីរភាព ហើយសង្គមជាតិមានការរីកចម្រើនគួរជាទីមោទនៈ។

ក្រសួងអភិវឌ្ឍន៍ជនបទ ដែលជាស្ថាប័នមានសមត្ថកិច្ចក្នុងការងារអភិវឌ្ឍន៍ជនបទ ពិសេសក្នុងការស្ថាបនា ការស្តារឡើងវិញ ការថែទាំ និងការជួសជុលហេដ្ឋារចនាសម្ព័ន្ធរូបវន្តគមនាគមន៍ជនបទ បាននិងកំពុងធ្វើឱ្យមានការប្រែប្រួលទាំងបរិមាណ និងគុណភាពក្នុងអត្រាគ្របដណ្តប់ប្រមាណ ៧៤% នៃផ្លូវថ្នល់ទូទាំងព្រះរាជាណាចក្រកម្ពុជា។ ផ្លូវជនបទ និងសំណង់សិល្បការ្យ បានដើរតួនាទីយ៉ាងសំខាន់ប្រកបដោយយុទ្ធសាស្ត្រក្នុងការធ្វើដំណើរ ការដឹកជញ្ជូន និងចរាចរណ៍បែងចែកកសិផលក៏ដូចជាទំនិញគ្រប់ប្រភេទនៅតាមតំបន់ជនបទ និងទូទាំងប្រទេស។ ជាក់ស្តែងការកែលម្អ ឬលើកកម្រិតផ្លូវជនបទពីផ្លូវដីទៅជាផ្លូវក្រាលក្រួសក្រហម ពីផ្លូវក្រាលក្រួសក្រហម ទៅជាផ្លូវក្រាលកៅស៊ូ និងផ្លូវក្រាលបេតុង គឺមិនត្រឹមតែបង្កលក្ខណៈងាយស្រួលដល់ការធ្វើដំណើររបស់ប្រជាពលរដ្ឋប៉ុណ្ណោះទេ ថែមទាំងបានកាត់បន្ថយពេលវេលា និងកាត់បន្ថយចំណាយទៀតផង។ លើសពីនេះទៅទៀត ប្រព័ន្ធផ្លូវគមនាគមន៍ជនបទ បាននិងកំពុងរួមចំណែកបង្កើនប្រាក់ចំណូលលើកកម្ពស់ជីវភាព និងកាត់បន្ថយភាពក្រីក្ររបស់ប្រជាពលរដ្ឋជនបទប្រកបដោយសមធម៌ និងបរិយាប័ន្ន។ សរុបមកនាពេលបច្ចុប្បន្ននេះ ផ្លូវជនបទកំពុងដើរតួនាទីយ៉ាងសំខាន់ក្នុងលំហូរនៃធាតុចូលនិងធាតុចេញរបស់តំបន់ជនបទ និងបម្រើដោយផ្ទាល់នូវសកម្មភាពសេដ្ឋកិច្ច។ ម្យ៉ាងទៀត ផ្លូវជនបទបាននិងកំពុងបង្កលក្ខណៈងាយស្រួលដល់ការធ្វើដំណើរ ការប្រាស្រ័យទាក់ទងគ្នារវាងប្រជាជនគ្រប់ច្រកល្ហក គ្រប់រដូវកាល សម្រួលគ្រប់សកម្មភាពសង្គមកិច្ច ក៏ដូចជាបង្វិតទីជនបទឱ្យនៅជិតគ្នា និងទីប្រជុំជន។

សៀវភៅទិន្នន័យសារពើភ័ណ្ឌផ្លូវជនបទទូទាំងប្រទេស ត្រូវបានបោះពុម្ពជាលើកដំបូងនៅឆ្នាំ ២០១៤ ក្រោយពីការចុះបញ្ជីសារពើភ័ណ្ឌផ្លូវជនបទតាមប្រព័ន្ធព័ត៌មានវិទ្យាត្រូវបានបង្កើត និងដាក់ឱ្យប្រើប្រាស់ និងធ្វើបច្ចុប្បន្នភាពប្រចាំខែ ដោយក្រុមការងារធ្វើបច្ចុប្បន្នភាពការគ្រប់គ្រងផ្លូវជនបទ។ ស្របតាមគោលការណ៍ធ្វើបច្ចុប្បន្នភាព សៀវភៅទិន្នន័យសារពើភ័ណ្ឌផ្លូវជនបទទូទាំងប្រទេស ត្រូវបានរៀបចំចងក្រង និងបោះពុម្ពរៀងរាល់ប្រាំឆ្នាំម្តង។ សៀវភៅទិន្នន័យសារពើភ័ណ្ឌផ្លូវជនបទទូទាំងប្រទេស ឆ្នាំ ២០២០ នេះ គឺជាការធ្វើបច្ចុប្បន្នភាពលើកទីមួយទៅលើការបោះពុម្ពដំបូងនៅឆ្នាំ ២០១៤ ដោយត្រូវបានរៀបចំចងក្រងបោះពុម្ពជាពីរប្រភេទផ្សេងគ្នាគឺ **"ទិន្នន័យសារពើភ័ណ្ឌផ្លូវជនបទទូទាំងប្រទេស"** ដែលរួមមានទិន្នន័យសរុបទាំង ២៥ រាជធានី ខេត្ត និង **"ទិន្នន័យសារពើភ័ណ្ឌផ្លូវជនបទរាជធានី ខេត្ត"** ដែលមានតែទិន្នន័យសម្រាប់រាជធានី ខេត្ត តែមួយប៉ុណ្ណោះ។

ការធ្វើបច្ចុប្បន្នភាពលើកនេះ ត្រូវបានផ្តោតជាសំខាន់ទៅលើវឌ្ឍនភាពនៃទិន្នន័យផ្លូវជនបទទាំងបួនប្រភេទដែលស្ថិតក្រោមសមត្ថកិច្ចរបស់ក្រសួងអភិវឌ្ឍន៍ជនបទដែលរួមមាន៖ **ប្រភេទទី១** ជាផ្លូវដែលភ្ជាប់ពីផ្លូវជាតិ ផ្លូវខេត្ត ឆ្ពោះទៅកាន់ទីរួមក្រុង ស្រុក ខណ្ឌ និងផ្លូវដែលភ្ជាប់ពីទីរួមក្រុង ស្រុក ខណ្ឌ ឆ្ពោះទៅកាន់ទីរួមក្រុង ស្រុក ខណ្ឌ **ប្រភេទទី២** ជាផ្លូវដែលភ្ជាប់ពីទីរួមក្រុង ស្រុក ខណ្ឌ ឆ្ពោះទៅកាន់ទីប្រជុំជនឃុំ សង្កាត់ **ប្រភេទទី៣** ជាផ្លូវដែលភ្ជាប់ពីទីប្រជុំជនឃុំ សង្កាត់ ឆ្ពោះទៅកាន់ទីប្រជុំជនឃុំ សង្កាត់ និង**ប្រភេទទី៤** ជាផ្លូវដែលភ្ជាប់ពីទីប្រជុំជនឃុំ សង្កាត់ ឆ្ពោះទៅកាន់ទីប្រជុំជនភូមិ ផ្លូវដែលភ្ជាប់ពីទីប្រជុំជនភូមិ ឆ្ពោះទៅកាន់ទីប្រជុំជនភូមិ និងផ្លូវក្នុងភូមិ។ ទន្ទឹមនឹងនេះ ក្នុងគោលដៅកំណត់ឱ្យបានច្បាស់លាស់នូវប្រភេទនៃខ្សែផ្លូវជនបទនីមួយៗ ក្រុមការងារបានរៀបចំបង្កើតប្រព័ន្ធគ្រប់គ្រង និងធ្វើបច្ចុប្បន្នភាពទិន្នន័យផ្លូវជនបទតាមប្រព័ន្ធព័ត៌មានភូមិសាស្ត្រ (Geographic Information System) និងបានបោះពុម្ពផែនទីខ្សែផ្លូវជនបទតាមបណ្តាក្រុង ស្រុក ខណ្ឌទាំង ២០៣ នៃរាជធានី ខេត្ត ទូទាំងប្រទេស។

ក្នុងនាមក្រសួងអភិវឌ្ឍន៍ជនបទ ខ្ញុំសូមវាយតម្លៃខ្ពស់ និងថ្លែងអំណរគុណ ចំពោះក្រុមការងារធ្វើបច្ចុប្បន្នភាពការគ្រប់គ្រងផ្លូវជនបទតាមប្រព័ន្ធព័ត៌មានវិទ្យា នៃក្រសួងអភិវឌ្ឍន៍ជនបទ ដែលដឹកនាំដោយ **ឯកឧត្តម ក្លូង សោភា** រដ្ឋលេខាធិការក្រសួងអភិវឌ្ឍន៍ជនបទ និងមន្ទីរអភិវឌ្ឍន៍ជនបទរាជធានី ខេត្តទាំងអស់ ដែលបានខិតខំប្រឹងប្រែងយកអស់កម្លាំងកាយចិត្តក្នុងការចុះប្រមូល និងបញ្ចូលទិន្នន័យទៅក្នុងប្រព័ន្ធព័ត៌មានវិទ្យា ដើម្បីធ្វើបច្ចុប្បន្នភាព និងរៀបចំបោះពុម្ពសៀវភៅទិន្នន័យសារពើភ័ណ្ឌនេះ រហូតសម្រេចបានជោគជ័យតាមការគ្រោងទុក។ ជាមួយគ្នានេះ ខ្ញុំក៏សូមថ្លែងអំណរគុណយ៉ាងជ្រាលជ្រៅផងដែរចំពោះ ឯកឧត្តម លោកជំទាវ លោក លោកស្រីជាថ្នាក់ដឹកនាំ និងគ្រប់អង្គភាពជំនាញនៃក្រសួងអភិវឌ្ឍន៍ជនបទទាំងអស់ ដែលបានរួមចំណែកជួយពិនិត្យ និងផ្តល់យោបល់កែលម្អប្រកបដោយស្មារតីទទួលខុសត្រូវខ្ពស់ និងបណ្តាដៃគូអភិវឌ្ឍន៍នានា ដែលបានផ្តល់កិច្ចសហប្រតិបត្តិការដ៏ល្អប្រសើរ ក្នុងការរួមចំណែកធ្វើឱ្យក្រសួងសម្រេចបាននូវសមិទ្ធផលដ៏មានសារៈសំខាន់នេះ។

ខ្ញុំសង្ឃឹមយ៉ាងមុតមាំថា សៀវភៅទិន្នន័យសារពើភ័ណ្ឌនេះនឹងក្លាយជាឧបករណ៍ដ៏មានសារៈសំខាន់ និងជាមូលដ្ឋានសម្រាប់ការរៀបចំគោលនយោបាយផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ និងការគ្រប់គ្រងហេដ្ឋារចនាសម្ព័ន្ធគមនាគមន៍របស់អង្គភាពក្រោមឱវាទក្រសួងអភិវឌ្ឍន៍ជនបទ។ ទន្ទឹមនឹងនេះ ក្រសួង ស្ថាប័នពាក់ព័ន្ធ ក្នុងវិស័យផ្លូវថ្នល់ និងរដ្ឋបាលថ្នាក់ក្រោមជាតិ ដៃគូអភិវឌ្ឍន៍ ព្រមទាំងអង្គការសង្គមស៊ីវិល អាចយកទៅប្រើប្រាស់តាមតម្រូវការចាំបាច់ ដើម្បីជាប្រយោជន៍ដល់ប្រជាពលរដ្ឋ និងសង្គមជាតិ។

ថ្ងៃព្រហស្បតិ៍ ៩រោច ខែស្រាពណ៍ ឆ្នាំជូត ទោស័ក ព.ស. ២៥៦៤
រាជធានីភ្នំពេញ ថ្ងៃទី ១៣ ខែសីហា ឆ្នាំ ២០២០
**រដ្ឋមន្ត្រី**

បណ្ឌិតសភាចារ្យ **អ៊ុក រ៉ាប៊ុន**

# សេចក្តីផ្តើម

សៀវភៅទិន្នន័យសារពើភ័ណ្ឌផ្លូវជនបទទូទាំងប្រទេស បានបោះពុម្ពជាលើកដំបូងនៅឆ្នាំ ២០១៤។ ការចុះបញ្ជីសារពើភ័ណ្ឌផ្លូវជនបទតាមប្រព័ន្ធព័ត៌មានវិទ្យា ត្រូវបានរៀបចំឡើង និងធ្វើបច្ចុប្បន្នភាពប្រចាំខែដោយក្រុមការងាររៀបចំបញ្ជីសារពើភ័ណ្ឌ និងប្រមូលទិន្នន័យផ្លូវជនបទ នៃព្រះរាជាណាចក្រកម្ពុជា ដែលបានបង្កើតឡើងក្នុងឆ្នាំ ២០១០។ តាមគោលការណ៍ច្បាប់ សៀវភៅទិន្នន័យសារពើភ័ណ្ឌផ្លូវជនបទទូទាំងប្រទេស ត្រូវបានបោះពុម្ពរៀងរាល់ប្រាំឆ្នាំម្តង ដោយនៅក្នុងឆ្នាំ ២០២០ នេះ គឺជាការធ្វើបច្ចុប្បន្នភាពលើកទីមួយទៅលើការបោះពុម្ពដំបូងនាឆ្នាំ ២០១៤ ដោយក្រុមការងារធ្វើបច្ចុប្បន្នភាពការគ្រប់គ្រងផ្លូវជនបទតាមប្រព័ន្ធព័ត៌មានវិទ្យារបស់ក្រសួងអភិវឌ្ឍន៍ជនបទ។

ការធ្វើបច្ចុប្បន្នភាពផ្លូវជនបទលើកនេះ ត្រូវបានពង្រីកវិសាលភាពគ្របដណ្តប់ទូទាំងប្រទេស និងបង្កើនបានភាពគ្រប់ជ្រុងជ្រោយដែលមានលក្ខណៈលម្អិតដល់គ្រប់ភូមិ ហើយគុណភាពផ្លូវជនបទក៏ត្រូវបានកែលម្អ ឬលើកកម្រិតពីប្រភេទផ្លូវដីទៅជាផ្លូវក្រាលក្រួសក្រហម ពីផ្លូវក្រាលក្រួសក្រហមទៅជាផ្លូវក្រាលកៅស៊ូ និងផ្លូវក្រាលបេតុង។ ប្រវែងផ្លូវត្រូវបានកើនឡើងគួរឱ្យកត់សម្គាល់ ពោលគឺផ្លូវជនបទដែលមានប្រវែង ៣៩,៧១១.០០ គ.ម នៅឆ្នាំ ២០១៤ ត្រូវបានកើនឡើងដល់ ៤៧,៩១៩.៥៣១ គ.ម នៅក្នុងអំឡុងខែមករា ឆ្នាំ ២០២០។

ដូចមាននៅក្នុងសៀវភៅទិន្នន័យសារពើភ័ណ្ឌដែលបានបោះពុម្ពលើកដំបូងដែរ ផ្លូវជនបទដែលស្ថិតក្រោមសមត្ថកិច្ចរបស់ក្រសួងអភិវឌ្ឍន៍ជនបទ ត្រូវបានរក្សាជាបួនប្រភេទដដែល៖ **ប្រភេទទី១** ជាផ្លូវដែលភ្ជាប់ពីផ្លូវជាតិ ផ្លូវខេត្ត ឆ្ពោះទៅកាន់ទីរួមក្រុង ស្រុក ខណ្ឌ និងផ្លូវដែលភ្ជាប់ពីទីរួមក្រុង ស្រុក ខណ្ឌ ឆ្ពោះទៅកាន់ទីរួមក្រុង ស្រុក ខណ្ឌ **ប្រភេទទី២** ជាផ្លូវដែលភ្ជាប់ពីទីរួមក្រុង ស្រុក ខណ្ឌ ឆ្ពោះទៅកាន់ទីប្រជុំជនឃុំ សង្កាត់ **ប្រភេទទី៣** ជាផ្លូវដែលភ្ជាប់ពីទីប្រជុំជនឃុំ សង្កាត់ ឆ្ពោះទៅកាន់ទីប្រជុំជនឃុំ សង្កាត់ និង**ប្រភេទទី៤** ជាផ្លូវដែលភ្ជាប់ពីទីប្រជុំជនឃុំ សង្កាត់ ឆ្ពោះទៅកាន់ទីប្រជុំជនភូមិ ផ្លូវដែលភ្ជាប់ពីទីប្រជុំជនភូមិឆ្ពោះទៅកាន់ទីប្រជុំជនភូមិ និងផ្លូវក្នុងភូមិ។ ទន្ទឹមនឹងនេះ ក្នុងគោលដៅកំណត់ឱ្យបានច្បាស់លាស់នូវប្រភេទខ្សែផ្លូវជនបទនីមួយៗ ក្រុមការងារបានរៀបចំបង្កើតប្រព័ន្ធគ្រប់គ្រង និងធ្វើបច្ចុប្បន្នភាពទិន្នន័យផ្លូវជនបទតាមប្រព័ន្ធព័ត៌មានភូមិសាស្ត្រ (Geographic Information System) និងបានបោះពុម្ពផែនទីខ្សែផ្លូវជនបទតាមបណ្តាក្រុង ស្រុក ខណ្ឌទាំង ២០៣ នៃរាជធានី ខេត្តទូទាំងប្រទេស។

សៀវភៅទិន្នន័យសារពើភ័ណ្ឌផ្លូវជនបទទូទាំងប្រទេស ដែលត្រូវបានធ្វើបច្ចុប្បន្នភាពលើកទីមួយនេះ ត្រូវបានបោះពុម្ពជាពីរប្រភេទផ្សេងគ្នា គឺ៖ ១).**ទិន្នន័យសារពើភ័ណ្ឌផ្លូវជនបទទូទាំងប្រទេស** ដែលមានទិន្នន័យ រួមទាំង ២៥ រាជធានី ខេត្ត និង២).**ទិន្នន័យសារពើភ័ណ្ឌផ្លូវជនបទរាជធានី ខេត្ត** ដែលមានទិន្នន័យសម្រាប់រាជធានី ខេត្តនីមួយៗដាច់ដោយឡែកពីគ្នា។ ចំពោះសៀវភៅប្រភេទទី១ នៅក្នុងតារាង ៣. ១ បានបង្ហាញអំពីប្រភេទនៃកម្រាលផ្លូវជនបទ និងប្រវែងសរុបដែលសម្រេចបានគិតត្រឹមខែមករា ឆ្នាំ ២០២០ គឺមានប្រវែងសរុប ៤៧,៩១៩.៥៣១ គ.ម ដែលក្នុងនោះ ប្រភេទកម្រាលកៅស៊ូមួយជាន់មានប្រវែងសរុប ៤០៨.៤៩៦ គ.ម កម្រាលកៅស៊ូពីរជាន់មានប្រវែងសរុប ៣,១៦៦.៤២៩ គ.ម កម្រាលបេតុងមានប្រវែងសរុប ៨២១.៣៣៩ គ.ម កម្រាលក្រួសក្រហមមានប្រវែងសរុប ២៧,៧៩៨.៩២៥ គ.ម កម្រាលល្បាយក្រួសអាចម៍ផ្កាយមានប្រវែងសរុប ១,៥១០.៧៦០ គ.ម កម្រាលល្បាយកំទេចថ្មភ្នំមានប្រវែងសរុប ២,៣០៥.៧៦៥ គ.ម កម្រាលដីសមានប្រវែងសរុប ៩,១៧១.២៥៩ គ.ម កម្រាលខ្សាច់ភ្នំមានប្រវែងសរុប ២,៤០៥.១៣១ គ.ម និងប្រភេទកម្រាលផ្សេងៗទៀតមានប្រវែងសរុប ៣៣១.៤២៧ គ.ម។ នៅក្នុងតារាង ៣.២ សៀវភៅនេះបានបង្ហាញអំពីសមិទ្ធផលដែលសម្រេចបាន ១០០% ធៀបនឹងផែនការដែលបានគ្រោងទុកពីឆ្នាំ ២០១០ ដល់ឆ្នាំ ២០២០។

លើសពីនេះ សៀវភៅក៏បានរៀបរាប់លម្អិតអំពីទីតាំង, ប្រវែងខ្សែផ្លូវ, ឈ្មោះផ្លូវ, និយាមកា, ទទឹងផ្លូវ, ប្រភេទកម្រាល, ប្រភេទខ្សែផ្លូវ, ប្រភពថវិកា, អ្នកទទួលការ, ឆ្នាំស្ថាបនា ស្តារឡើងវិញ ថែទាំ និងជួសជុលផ្លូវជនបទនិងសំណង់សិល្បការ្យ, និងផែនទីផ្លូវជនបទនៅតាមបណ្តារាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ ។ ចំពោះសៀវភៅប្រភេទទី ២ ក៏មិនខុសពីសៀវភៅប្រភេទទី ១ ដែរ គឺមានតារាង ៣.១, តារាង ៣.២, ទីតាំងខ្សែផ្លូវ, និងផែនទីខ្សែផ្លូវនៅតាមបណ្តារាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ ដូចគ្នា។ សៀវភៅប្រភេទទី ២ នេះ ដកស្រង់យកតែទិន្នន័យសម្រាប់ខេត្តស្ទឹងត្រែងមួយមកបោះពុម្ពតែប៉ុណ្ណោះ។

ជាងនេះទៅទៀត សៀវភៅនេះមានការពិពណ៌នាពីប្រព័ន្ធកូអរដោនេភូមិសាស្ត្រច្បាស់លាស់ ដោយខ្សែផ្លូវនីមួយៗមានលេខកូដមួយជាសម្គាល់ (លេខកូដនេះមិនមែនជាលេខផ្លូវជនបទទេ)។ ចំណែកឯផែនទីខ្សែផ្លូវជនបទ ត្រូវបានរៀបតាមលេខកូដរាជធានី ខេត្ត ក្រុង ស្រុក និងខណ្ឌ ដែលបានកំណត់ឱ្យប្រើប្រាស់ជាផ្លូវការដោយក្រសួងមហាផ្ទៃ។ ឈ្មោះផ្លូវដែលក្រុមការងារបានដាក់ក្នុងសៀវភៅទិន្នន័យសារពើភ័ណ្ឌនេះ ជាឈ្មោះក្រៅផ្លូវការនៅឡើយ ដោយឈ្មោះផ្លូវភាគច្រើនកើតពីបន្សំរវាងឈ្មោះភូមិ ឬទីប្រជុំជន ត្រង់ចំណុចចាប់ផ្តើមនៃផ្លូវ និងឈ្មោះភូមិ ឬទីប្រជុំជនត្រង់ចំណុចបញ្ចប់នៃផ្លូវ។ ទន្ទឹមនឹងនេះ ក្រុមការងារក៏បានស្រង់ឈ្មោះផ្លូវមួយចំនួនដែលប្រជាជនប្រើប្រាស់ជាក់ស្តែងយកមកដាក់ក្នុងបញ្ជីផងដែរ។

ព័ត៌មានអំពីឆ្នាំជួសជុលសំដៅលើ ឆ្នាំចុងក្រោយដែលប្រតិបត្តិការសាងសង់ កែលម្អ ជួសជុល ឬ ថែទាំផ្លូវជនបទត្រូវបានអនុវត្ត។ ចំពោះព័ត៌មានអំពីសំណង់សិល្បការ្យ សៀវភៅនេះបានបង្ហាញតែចំនួនសរុបរបស់លូ និងស្ពាននៅតាមបណ្តោយខ្សែផ្លូវនីមួយៗប៉ុណ្ណោះ។ រីឯទិន្នន័យលម្អិតរបស់សំណង់សិល្បការ្យ និងទិន្នន័យសំណង់រដ្ឋបាលសាធារណៈដទៃទៀត ដែលមាននៅតាមបណ្តោយខ្សែផ្លូវជនបទនីមួយៗ រួមមាន វត្តអារាម ផ្សារ សាលារៀន មណ្ឌលសុខភាព សាលាស្រុក សាលាឃុំ ប៉ុស្តិ៍នគរបាល ស្នាក់ការភូមិ វិហារអ៊ីស្លាម។ល។ មានរក្សាទុកនៅក្នុងប្រព័ន្ធទិន្នន័យកូអរដោនេភូមិសាស្ត្រផ្លូវជនបទរបស់ក្រសួងអភិវឌ្ឍន៍ជនបទ សម្រាប់បោះពុម្ពផែនទីខ្នាតធំ។

សៀវភៅទិន្នន័យបញ្ជីសារពើភ័ណ្ឌផ្លូវជនបទនេះ ជាឧបករណ៍មានសារៈសំខាន់ក្នុងការជួយដល់អង្គភាពជំនាញពាក់ព័ន្ធចំណុះក្រសួងអភិវឌ្ឍន៍ជនបទផ្ទាល់ ក៏ដូចជាក្រសួង ស្ថាប័ន រដ្ឋបាលថ្នាក់ក្រោមជាតិ ដៃគូជាតិ និងអន្តរជាតិ ព្រមទាំងវិស័យឯកជន។ល។ ក្នុងការរៀបចំផែនការ កម្មវិធីនយោបាយអភិវឌ្ឍន៍ផ្លូវថ្នល់ ការងារគ្រប់គ្រង និងប្រើប្រាស់ផ្លូវជនបទប្រកបដោយប្រសិទ្ធភាព។

**មាតិកា** **ទំព័រ**


បុព្វកថា I
សេចក្តីផ្តើម II
មាតិកា III
១-ព័ត៌មានទូទៅ និងវាក្យសព្ទគន្លឹះ ១
២-វិធីសាស្ត្រក្នុងការប្រមូលទិន្នន័យ ២
៣-ទិន្នន័យសរុបនៃប្រភេទកម្រាលនិងប្រវែងផ្លូវជនបទ និងលទ្ធផលសារពើភ័ណ្ឌផ្លូវជនបទ ២០១០-២០២០ ២
តារាង ៣.១. ប្រភេទកម្រាល និងប្រវែងផ្លូវជនបទទូទាំងប្រទេស ៣
តារាង ៣.២. លទ្ធផលសារពើភ័ណ្ឌផ្លូវជនបទ ២០១០-២០២០ ៤
៤- ទិន្នន័យសារពើភ័ណ្ឌផ្លូវជនបទខេត្តស្ទឹងត្រែង ៥
**១៩ ខេត្តស្ទឹងត្រែង** ៦
តារាងប្រភេទកម្រាល និងប្រវែងផ្លូវជនបទខេត្តស្ទឹងត្រែង ៧
ក្រាហ្វិកប្រភេទកម្រាល និងប្រវែងផ្លូវជនបទខេត្តស្ទឹងត្រែង ៨
តារាងលទ្ធផលសារពើភ័ណ្ឌផ្លូវជនបទ ២០១០-២០២០ ខេត្តស្ទឹងត្រែង ៩
ផែនទីផ្លូវជនបទខេត្តស្ទឹងត្រែង ១០
*១៩០១ ស្រុកសេសាន* ១១
តារាងលទ្ធផលសារពើភ័ណ្ឌផ្លូវជនបទ ២០១០-២០២០ ស្រុកសេសាន ១២
ក្រាហ្វិកប្រភេទកម្រាល និងប្រវែងផ្លូវជនបទស្រុកសេសាន ១៦
ផែនទីផ្លូវជនបទស្រុកសេសាន ១៧
*១៩០២ ស្រុកសៀមបូក* ១៨
តារាងលទ្ធផលសារពើភ័ណ្ឌផ្លូវជនបទ ២០១០-២០២០ ស្រុកសៀមបូក ១៩
ក្រាហ្វិកប្រភេទកម្រាល និងប្រវែងផ្លូវជនបទស្រុកសៀមបូក ២១
ផែនទីផ្លូវជនបទស្រុកសៀមបូក ២២
*១៩០៣ ស្រុកសៀមប៉ាង* ២៣
តារាងលទ្ធផលសារពើភ័ណ្ឌផ្លូវជនបទ ២០១០-២០២០ ស្រុកសៀមប៉ាង ២៤
ក្រាហ្វិកប្រភេទកម្រាល និងប្រវែងផ្លូវជនបទស្រុកសៀមប៉ាង ២៦
ផែនទីផ្លូវជនបទស្រុកសៀមប៉ាង ២៧
*១៩០៤ ក្រុងស្ទឹងត្រែង* ២៨
តារាងលទ្ធផលសារពើភ័ណ្ឌផ្លូវជនបទ ២០១០-២០២០ ក្រុងស្ទឹងត្រែង ២៩
ក្រាហ្វិកប្រភេទកម្រាល និងប្រវែងផ្លូវជនបទក្រុងស្ទឹងត្រែង ៣១
ផែនទីផ្លូវជនបទក្រុងស្ទឹងត្រែង ៣២
*១៩០៥ ស្រុកថាឡាបរិវ៉ាត់* ៣៣
តារាងលទ្ធផលសារពើភ័ណ្ឌផ្លូវជនបទ ២០១០-២០២០ ស្រុកថាឡាបរិវ៉ាត់ ៣៤
ក្រាហ្វិកប្រភេទកម្រាល និងប្រវែងផ្លូវជនបទស្រុកថាឡាបរិវ៉ាត់ ៣៦
ផែនទីផ្លូវជនបទស្រុកថាឡាបរិវ៉ាត់ ៣៧
*១៩០៦ ស្រុកបុរីអូរស្វាយសែនជ័យ* ៣៨
តារាងលទ្ធផលសារពើភ័ណ្ឌផ្លូវជនបទ ២០១០-២០២០ ស្រុកបុរីអូរស្វាយសែនជ័យ ៣៩
ក្រាហ្វិកប្រភេទកម្រាល និងប្រវែងផ្លូវជនបទស្រុកបុរីអូរស្វាយសែនជ័យ ៤១
ផែនទីផ្លូវជនបទស្រុកបុរីអូរស្វាយសែនជ័យ ៤២

## ១- ព័ត៌មានទូទៅ និងវាក្យសព្ទគន្លឹះ

| ព័ត៌មានទូទៅ | |
|---|---|
| ផ្ទៃដីសរុបៈ គម² | ១៨១ ០៣៥ |
| ចំនួនរាជធានី | ១ |
| ចំនួនខេត្ត | ២៤ |
| ចំនួនក្រុង | ២៧ |
| ចំនួនខណ្ឌ | ១៤ |
| ចំនួនស្រុក | ១៦២ |
| ចំនួនសង្កាត់ | ២៤១ |
| ចំនួនឃុំ | ១ ៤០៥ |
| ចំនួនភូមិ | ១៤ ៣៨៣ |

### វាក្យសព្ទគន្លឹះ

១- **លេខ 47.908 គ.ម** អានថា សែសិបប្រាំពីរគីឡូម៉ែត្រ និងប្រាំបួនរយប្រាំបីម៉ែត្រ។

២- **លេខ 1,822.173 គ.ម** អានថា មួយពាន់ប្រាំបីរយម្ភៃពីរគីឡូម៉ែត្រ និងមួយរយចិតសិបបីម៉ែត្រ។

៣- **បញ្ជីសារពើភ័ណ្ឌផ្លូវជនបទ** សំដៅដល់កំណត់ត្រាទ្រព្យសម្បត្តិផ្លូវជនបទទាំងអស់។

៤- **ទិន្នន័យផ្លូវជនបទ** សំដៅដល់ទិន្នន័យជាបរិមាណ និងគុណភាព របស់ផ្លូវជនបទ។

៥- **ផ្លូវថ្នល់** សំដៅដល់ទំហំផ្លូវទាំងមូលរួមមាន តួផ្លូវ ទ្រូងផ្លូវ ជាយផ្លូវ ឬចិញ្ចើមផ្លូវ។

៦- **សំណង់សិល្បការ្យ** សំដៅដល់សំណង់ស្ពាន លូ ជញ្ជាំងទប់ដី ប្រព័ន្ធរំដោះទឹក និងសំណង់រូបវន្តផ្សេងទៀតដែលផ្តល់សុវត្ថិភាព ប្រសិទ្ធភាព និងស្ថិរភាព ដល់ផ្លូវថ្នល់។

៧-**ផ្លូវជាតិ** សំដៅដល់ផ្លូវដែលមានចរាចរណ៍ច្រើនៈ

- ក-ផ្លូវភ្ជាប់ចេញពីរាជធានីភ្នំពេញឆ្ពោះទៅកាន់ក្រុងនៃខេត្តនីមួយៗនៅទូទាំងប្រទេស។
- ខ-ផ្លូវភ្ជាប់ចេញពីក្រុងនៃខេត្តមួយ ឆ្ពោះទៅកាន់ក្រុងនៃខេត្តមួយទៀត។
- គ-ផ្លូវភ្ជាប់ចេញពីផ្លូវជាតិ ឆ្ពោះទៅកាន់ផ្លូវជាតិ។
- ឃ-ផ្លូវបែកចេញពីផ្លូវជាតិ ឆ្ពោះទៅកាន់ក្រុងនៃខេត្តមួយ។
- ង-ផ្លូវបែកចេញពីផ្លូវជាតិ ឬផ្លូវភ្ជាប់ចេញពីក្រុងនៃខេត្តមួយ ឆ្ពោះទៅកាន់តំបន់សំខាន់ៗ ដូចជា កំពង់ផែ ស្ថានីយរថភ្លើង អាកាសយានដ្ឋាន តំបន់សេដ្ឋកិច្ចពិសេស រមណីយដ្ឋានទេសចរណ៍ ច្រកទ្វារព្រំដែន តំបន់មានសក្តានុពលសេដ្ឋកិច្ចសំខាន់ៗផ្សេងទៀត។
- ច-ផ្លូវសំខាន់ៗរបស់ជាតិ មានចរាចរណ៍ច្រើនដែលកំណត់ដោយរាជរដ្ឋាភិបាល តាមសំណើរបស់ ក្រសួងសាធារណការ និងដឹកជញ្ជូន។

៨-**ផ្លូវខេត្ត** សំដៅដល់ផ្លូវដែលមានចរាចរណ៍មធ្យម ៖

- ក-ផ្លូវភ្ជាប់ចេញពីក្រុងនៃខេត្តមួយ ឆ្ពោះទៅកាន់ទីរួមស្រុក ខណ្ឌ។
- ខ-ផ្លូវបែកចេញពីផ្លូវជាតិ ឆ្ពោះទៅកាន់ផ្លូវខេត្ត។
- គ-ផ្លូវបែកចេញពីផ្លូវខេត្ត ឬផ្លូវក្រុង ឆ្ពោះទៅកាន់ផ្លូវទីរួមស្រុក ខណ្ឌ។
- ឃ-ផ្លូវភ្ជាប់ចេញពីក្រុងនៃខេត្តមួយ ឆ្ពោះទៅកាន់ផ្លូវខេត្ត។
- ង-ផ្លូវបែកចេញពីខេត្ត ឆ្ពោះទៅកាន់ផ្លូវខេត្ត។
- ច-ផ្លូវបែកចេញពីផ្លូវខេត្ត ឬផ្លូវក្រុង ឬផ្លូវទីប្រជុំជននានាក្នុងខេត្តទៅកាន់តំបន់សំខាន់ៗ ដូចជា កំពង់ផែ ស្ថានីយរថភ្លើង អាកាសយានដ្ឋាន តំបន់សេដ្ឋកិច្ចពិសេស រមណីយដ្ឋានទេសចរណ៍ ច្រកទ្វារព្រំដែនទ្វេភាគី តំបន់មានសក្តានុពលសេដ្ឋកិច្ចមធ្យមផ្សេងទៀត។

៩-**ផ្លូវជនបទ** សំដៅដល់ៈ

- ក-ផ្លូវដែលភ្ជាប់ពីផ្លូវជាតិ ផ្លូវខេត្ត ឆ្ពោះទៅកាន់ក្រុង ទីរួមស្រុក ខណ្ឌ ទីប្រជុំជនឃុំ សង្កាត់ និងទៅភូមិ។
- ខ-ផ្លូវដែលភ្ជាប់ពីក្រុង ទីរួមស្រុក ខណ្ឌ ឆ្ពោះទៅកាន់ក្រុង ទីរួមស្រុក ខណ្ឌ។
- គ-ផ្លូវដែលភ្ជាប់ពីក្រុង ទីរួមស្រុក ខណ្ឌ ទៅទីប្រជុំជនឃុំ សង្កាត់។
- ឃ-ផ្លូវដែលភ្ជាប់ពីទីប្រជុំជនឃុំ សង្កាត់ ទៅទីប្រជុំជនឃុំ សង្កាត់។
- ង-ផ្លូវដែលភ្ជាប់ពីទីប្រជុំជនឃុំ សង្កាត់ទៅភូមិ។
- ច-ផ្លូវដែលភ្ជាប់ពីភូមិទៅភូមិ។
- ឆ-ផ្លូវក្នុងភូមិ។

## ២- វិធីសាស្ត្រក្នុងការប្រមូលទិន្នន័យ

ទិន្នន័យផ្លូវជនបទ និងសំណង់សិល្បការ្យត្រូវបានរៀបចំចងក្រងនិងបោះពុម្ពឡើងនូវរៀងរាល់ប្រាំឆ្នាំម្តង។ ក្រសួងអភិវឌ្ឍន៍ជនបទបានរៀបចំបង្កើតក្រុមការងារធ្វើបច្ចុប្បន្នភាពការគ្រប់គ្រងផ្លូវជនបទតាមប្រព័ន្ធព័ត៌មានវិទ្យា ដែលមានសមាសភាពគ្រប់ថ្នាក់ចូលរួមចាប់តាំងពីរដ្ឋបាលកណ្តាលរហូតដល់មន្ទីរអភិវឌ្ឍន៍ជនបទរាជធានី ខេត្ត។ ក្រុមការងារបានចុះស្រង់ទិន្នន័យនិងធ្វើបច្ចុប្បន្នភាពខ្សែផ្លូវជនបទគ្រប់ប្រភេទនៅតាមបណ្តាក្រុង ស្រុក ខណ្ឌ នៃរាជធានី ខេត្តទាំង ២៥ និងទូទាំងប្រទេស និងដាក់បញ្ចូលក្នុងប្រព័ន្ធព័ត៌មានវិទ្យានៅរៀងរាល់ខែ។

## ៣- ទិន្នន័យសរុបនៃប្រភេទកម្រាលនិងប្រវែងផ្លូវជនបទ និងលទ្ធផលសារពើភ័ណ្ឌផ្លូវជនបទ ២០១០-២០២០

ផ្លូវជនបទសរុបត្រូវបានស្ថាបនា ស្តារឡើងវិញ ថែទាំ និងជួសជុលទៅតាមប្រភេទកម្រាលផ្សេងៗពីគ្នា ដូចមានចែងនៅក្នុងតារាង ៣.១ ស្តីពីប្រភេទកម្រាល និងប្រវែងផ្លូវជនបទទូទាំងប្រទេស និងសមិទ្ធផលដែលក្រសួងអភិវឌ្ឍន៍ជនបទសម្រេចបានពីឆ្នាំ២០១០ ដល់អំឡុងខែមករា ឆ្នាំ២០២០ ដូចមានចែងនៅក្នុងតារាង ៣.២ ស្តីពីលទ្ធផលសារពើភ័ណ្ឌផ្លូវជនបទ ២០១០-២០២០។

ដោយឡែកនៅខេត្តស្ទឹងត្រែង សៀវភៅទិន្នន័យសារពើភ័ណ្ឌផ្លូវជនបទបានបញ្ជាក់លម្អិតអំពីប្រភេទកម្រាលនិងប្រវែងផ្លូវជនបទ ក្រាហ្វិក ផែនទីខ្សែផ្លូវ និងលទ្ធផលសារពើភ័ណ្ឌផ្លូវជនបទរបស់ខេត្ត ក្រុង ស្រុក ឃុំ សង្កាត់ និងភូមិ។

# តារាង ៣.១ ប្រភេទកម្រាល និងប្រវែងផ្លូវជនបទទូទាំងប្រទេស

| ល.រ | រាជធានី-ខេត្ត | សរុប | | កៅស៊ូ ១ ជាន់ | កៅស៊ូ ២ ជាន់ | បេតុង | គ្រួសក្រហម | ល្បាយគ្រួស អាចម៍ផ្កាយ | ល្បាយកំទេច ថ្មត្ដី | ដីស | ខ្សាច់ត្អី | ផ្សេងៗ |
|---|---|---|---|---|---|---|---|---|---|---|---|---|
| | | ខ្សែ | ប្រវែង (គ.ម) | ប្រវែង (គ.ម) | ប្រវែង (គ.ម) | ប្រវែង (គ.ម) | ប្រវែង (គ.ម) | ប្រវែង (គ.ម) | ប្រវែង (គ.ម) | ប្រវែង (គ.ម) | ប្រវែង (គ.ម) | ប្រវែង (គ.ម) |
| ០១ | បន្ទាយមានជ័យ | 2,067 | 2,925.026 | 47.908 | 272.702 | 100.387 | 1,822.173 | 80.884 | 60.128 | 540.844 | | |
| ០២ | បាត់ដំបង | 2,140 | 5,554.310 | 7.009 | 503.626 | 32.062 | 3,630.711 | 17.909 | 438.168 | 907.861 | | 16.964 |
| ០៣ | កំពង់ចាម | 508 | 1,807.141 | 17.000 | 217.565 | 101.128 | 1,128.805 | | 113.464 | 209.531 | 19.648 | |
| ០៤ | កំពង់ឆ្នាំង | 656 | 1,855.910 | | 261.595 | | 1,486.455 | | 43.730 | 64.130 | | |
| ០៥ | កំពង់ស្ពឺ | 1,273 | 2,978.000 | 20.400 | 334.770 | 46.770 | 1,824.000 | | 283.470 | 316.660 | 147.510 | 4.420 |
| ០៦ | កំពង់ធំ | 1,108 | 2,658.175 | 0.826 | 130.257 | 6.689 | 1,848.024 | | 2.000 | 670.379 | | |
| ០៧ | កំពត | 724 | 2,105.263 | 9.150 | 14.000 | 18.790 | 1,892.374 | | 8.911 | 162.038 | | |
| ០៨ | កណ្ដាល | 1,047 | 2,377.060 | | 59.500 | 40.950 | 745.490 | | 140.720 | 1,303.000 | 76.660 | 10.740 |
| ០៩ | កោះកុង | 131 | 488.416 | | 9.700 | 4.237 | 415.913 | | 11.777 | 46.789 | | |
| ១០ | ក្រចេះ | 248 | 2,244.339 | | | | 1,663.344 | 324.385 | 46.800 | 209.810 | | |
| ១១ | មណ្ឌលគិរី | 66 | 479.040 | | | 2.120 | 148.920 | | 258.800 | 69.200 | | |
| ១២ | ភ្នំពេញ | 187 | 561.301 | | 29.200 | 335.123 | 48.600 | 83.687 | 5.970 | 48.991 | 9.730 | |
| ១៣ | ព្រះវិហារ | 472 | 1,586.859 | | 119.110 | 3.985 | 1,309.626 | | | 154.138 | | |
| ១៤ | ព្រៃវែង | 1,097 | 3,557.422 | 0.775 | 316.127 | 8.168 | 801.802 | | | 1,668.078 | 762.472 | |
| ១៥ | ពោធិ៍សាត់ | 599 | 1,884.995 | | 239.971 | | 1,191.744 | | | 443.852 | | 9.428 |
| ១៦ | រតនគិរី | 332 | 1,047.534 | | 64.200 | 0.974 | 884.016 | | 1.000 | 93.944 | 3.400 | |
| ១៧ | សៀមរាប | 819 | 2,789.899 | 101.400 | 132.000 | 11.895 | 1,659.235 | | | 885.369 | | |
| ១៨ | ព្រះសីហនុ | 202 | 381.503 | 12.500 | 32.000 | 33.377 | 110.714 | | 179.932 | 12.980 | | |
| ១៩ | ស្ទឹងត្រែង | 170 | 1,159.413 | | 15.100 | | 44.709 | 839.438 | | 260.166 | | |
| ២០ | ស្វាយរៀង | 764 | 2,714.211 | 181.428 | 45.600 | 16.771 | 1,068.241 | | 6.920 | 133.715 | 1,261.536 | |
| ២១ | តាកែវ | 689 | 2,399.939 | | 153.400 | | 978.877 | | 298.948 | 566.000 | 115.039 | 287.675 |
| ២២ | ឧត្ដរមានជ័យ | 383 | 1,222.779 | 2.400 | 97.770 | | 999.120 | | | 123.489 | | |
| ២៣ | កែប | 67 | 165.893 | | 3.000 | 1.136 | 67.378 | | 81.602 | 12.777 | | |
| ២៤ | ប៉ៃលិន | 168 | 517.091 | | 13.730 | | 33.007 | | 322.495 | 145.659 | | 2.200 |
| ២៥ | ត្បូងឃ្មុំ | 794 | 2,458.012 | 7.700 | 101.506 | 56.777 | 1,995.647 | 164.457 | 0.930 | 121.859 | 9.136 | |
| សរុបរួម (គ.ម) | | 16,711 | 47,919.531 | 408.496 | 3,166.429 | 821.339 | 27,798.925 | 1,510.760 | 2,305.765 | 9,171.259 | 2,405.131 | 331.427 |

## តារាង ៣.២ លទ្ធផលសារពើភ័ណ្ឌផ្លូវជនបទ ២០១០-២០២០

| ល.រ | រាជធានី-ខេត្ត | ផែនការសរុប (២០១០-២០២០) | | ដើមគ្រា (២០១៤) | | ផែនការ និងការអនុវត្ត (២០១៥-២០២០) | | | | | បូកយោងអនុវត្តសរុប | | % អនុវត្ត |
|---|---|---|---|---|---|---|---|---|---|---|---|---|---|
| | | | | | | ផែនការ | | ក្នុងគ្រា | | | | | |
| | | ខ្សែ | គ.ម | ខ្សែ | គ.ម | ខ្សែ | គ.ម | ខ្សែ | គ.ម | % អនុវត្ត | ខ្សែ | គ.ម | |
| 1 | 2 | 3 | 4 | 5 | 6 | 7 | 8 | 9 | 10 | 11=10/8 | 12=5+9 | 13=6+10 | 14=13/4 |
| ០១ | បន្ទាយមានជ័យ | 2,067 | 2,925.026 | 1,983 | 2,723.437 | 84 | 201.589 | 84 | 201.589 | 100% | 2,067 | 2,925.026 | 100% |
| ០២ | បាត់ដំបង | 2,140 | 5,554.310 | 1,865 | 4,285.927 | 275 | 1268.383 | 275 | 1,268.383 | 100% | 2,140 | 5,554.310 | 100% |
| ០៣ | កំពង់ចាម | 508 | 1,807.141 | 288 | 1,390.348 | 220 | 416.793 | 220 | 416.793 | 100% | 508 | 1,807.141 | 100% |
| ០៤ | កំពង់ឆ្នាំង | 656 | 1,855.910 | 399 | 1,344.662 | 257 | 511.248 | 257 | 511.248 | 100% | 656 | 1,855.910 | 100% |
| ០៥ | កំពង់ស្ពឺ | 1,273 | 2,978.000 | 1,167 | 2,803.000 | 106 | 175.000 | 106 | 175.000 | 100% | 1,273 | 2,978.000 | 100% |
| ០៦ | កំពង់ធំ | 1,108 | 2,658.175 | 858 | 2,217.729 | 250 | 440.446 | 250 | 440.446 | 100% | 1,108 | 2,658.175 | 100% |
| ០៧ | កំពត | 724 | 2,105.263 | 655 | 1,951.190 | 69 | 154.073 | 69 | 154.073 | 100% | 724 | 2,105.263 | 100% |
| ០៨ | កណ្ដាល | 1,047 | 2,377.060 | 1,016 | 2,226.330 | 31 | 150.730 | 31 | 150.730 | 100% | 1,047 | 2,377.060 | 100% |
| ០៩ | កោះកុង | 131 | 488.416 | 112 | 418.151 | 19 | 70.265 | 19 | 70.265 | 100% | 131 | 488.416 | 100% |
| ១០ | ក្រចេះ | 248 | 2,244.339 | 211 | 1,982.857 | 37 | 261.482 | 37 | 261.482 | 100% | 248 | 2,244.339 | 100% |
| ១១ | មណ្ឌលគិរី | 66 | 479.040 | 27 | 291.600 | 39 | 187.440 | 39 | 187.440 | 100% | 66 | 479.040 | 100% |
| ១២ | ភ្នំពេញ | 187 | 561.301 | 180 | 542.761 | 7 | 18.540 | 7 | 18.540 | 100% | 187 | 561.301 | 100% |
| ១៣ | ព្រះវិហារ | 472 | 1,586.859 | 349 | 1,200.175 | 123 | 386.684 | 123 | 386.684 | 100% | 472 | 1,586.859 | 100% |
| ១៤ | ព្រៃវែង | 1,097 | 3,557.422 | 719 | 3,137.853 | 378 | 419.569 | 378 | 419.569 | 100% | 1,097 | 3,557.422 | 100% |
| ១៥ | ពោធិ៍សាត់ | 599 | 1,884.995 | 464 | 1,585.565 | 135 | 299.430 | 135 | 299.430 | 100% | 599 | 1,884.995 | 100% |
| ១៦ | រតនគិរី | 332 | 1,047.534 | 285 | 888.006 | 47 | 159.528 | 47 | 159.528 | 100% | 332 | 1,047.534 | 100% |
| ១៧ | សៀមរាប | 819 | 2,789.899 | 388 | 2,055.390 | 431 | 734.509 | 431 | 734.509 | 100% | 819 | 2,789.899 | 100% |
| ១៨ | ព្រះសីហនុ | 202 | 381.503 | 175 | 314.676 | 27 | 66.827 | 27 | 66.827 | 100% | 202 | 381.503 | 100% |
| ១៩ | ស្ទឹងត្រែង | 170 | 1,159.413 | 53 | 560.339 | 117 | 599.074 | 117 | 599.074 | 100% | 170 | 1,159.413 | 100% |
| ២០ | ស្វាយរៀង | 764 | 2,714.211 | 635 | 2,481.998 | 129 | 232.213 | 129 | 232.213 | 100% | 764 | 2,714.211 | 100% |
| ២១ | តាកែវ | 689 | 2,399.939 | 602 | 2,217.182 | 87 | 182.757 | 87 | 182.757 | 100% | 689 | 2,399.939 | 100% |
| ២២ | ឧត្តរមានជ័យ | 383 | 1,222.779 | 263 | 898.254 | 120 | 324.525 | 120 | 324.525 | 100% | 383 | 1,222.779 | 100% |
| ២៣ | កែប | 67 | 165.893 | 54 | 102.237 | 13 | 63.656 | 13 | 63.656 | 100% | 67 | 165.893 | 100% |
| ២៤ | ប៉ៃលិន | 168 | 517.091 | 142 | 382.952 | 26 | 134.139 | 26 | 134.139 | 100% | 168 | 517.091 | 100% |
| ២៥ | ត្បូងឃ្មុំ | 794 | 2,458.012 | 458 | 1,881.660 | 336 | 576.352 | 336 | 576.352 | 100% | 794 | 2,458.012 | 100% |
| | សរុបរួម | 16,711 | 47,919.531 | 13,348 | 39,884.279 | 3,363 | 8,035.252 | 3,363 | 8,035.252 | 100% | 16,711 | 47,919.531 | 100% |

**៤-ទិន្នន័យសារពើភ័ណ្ឌផ្លូវជនបទខេត្តស្ទឹងត្រែង**

ខេត្តស្ទឹងត្រែងមានចំនួន ០៥ ស្រុក និង ០១ ក្រុង ។ ទិន្នន័យសារពើភ័ណ្ឌផ្លូវជនបទខេត្តស្ទឹងត្រែង បានរៀបចំធ្វើបច្ចុប្បន្នភាពនៅរៀងរាល់ខែ នឹងដាក់បញ្ចូលក្នុងប្រព័ន្ធព័ត៌មានវិទ្យា។ ទិន្នន័យទាំងនេះ ក្រសួងអភិវឌ្ឍន៍ជនបទ បានជ្រើសរើសតែខ្សែផ្លូវណាដែលស្ថិតក្រោមសមត្ថកិច្ចរបស់ខ្លួន រួចរៀបចំឱ្យក្លាយជាបញ្ជីសារពើភ័ណ្ឌផ្លូវជនបទខេត្តស្ទឹងត្រែង។

ការបោះពុម្ពលើកទី ២ នេះ ទិន្នន័យសារពើភ័ណ្ឌផ្លូវជនបទខេត្តស្ទឹងត្រែង បានគ្របដណ្តប់ដល់ភូមិ ហើយបានរៀបចំទៅតាមលំដាប់លេខកូដខេត្ត ស្រុក និងក្រុង រួមមាន ខេត្តស្ទឹងត្រែងលេខកូដ ១៩ ស្រុកសេសានលេខកូដ ១៩០១ ស្រុកសៀមបូកលេខកូដ ១៩០២ ស្រុកសៀមប៉ាងលេខកូដ ១៩០៣ ក្រុងស្ទឹងត្រែងលេខកូដ ១៩០៤ ស្រុកថាឡាបរិវ៉ាត់លេខកូដ ១៩០៥ និងស្រុកបុរីអូរស្វាយសែនជ័យលេខកូដ ១៩០៦។

# ១៩- ខេត្តស្ទឹងត្រែង

**ខេត្តស្ទឹងត្រែង មាន ០៥ ស្រុក និង ០១ ក្រុង រួមមាន៖**

**១៩០១- ស្រុកសេសាន**

**១៩០២- ស្រុកសៀមបូក**

**១៩០៣- ស្រុកសៀមប៉ាង**

**១៩០៤- ក្រុងស្ទឹងត្រែង**

**១៩០៥- ស្រុកថាឡាបរិវ៉ាត់**

**១៩០៦- ស្រុកបុរីអូរស្វាយសែនជ័យ**

## តារាងប្រភេទកម្រាល និងប្រវែងផ្លូវជនបទខេត្តស្ទឹងត្រែង

| ល.រ | ប្រភេទកម្រាល | ប្រវែង (គ.ម) |
|---|---|---|
| ១ | កៅស៊ូ ១ ជាន់ | |
| ២ | កៅស៊ូ ២ ជាន់ | 15.100 |
| ៣ | បេតុង | |
| ៤ | ក្រួសក្រហម | 44.709 |
| ៥ | ល្បាយក្រួសអាចម៍ផ្កាយ | 839.438 |
| ៦ | ល្បាយកំទេចថ្មភ្លឺ | |
| ៧ | ដីស | 260.166 |
| ៨ | ខ្សាច់ភ្លឺ | |
| ៩ | ផ្សេងៗ | |
| | សរុប | 1,159.413 |

# ក្រាហ្វិកប្រភេទកម្រាល និងប្រវែងផ្លូវជនបទខេត្តស្ទឹងត្រែង




| | កៅស៊ូ ១ ជាន់ | កៅស៊ូ ២ ជាន់ | បេតុង | ក្រួសក្រហម | ល្បាយក្រួសអាចម៍ផ្កាយ | ល្បាយកំទេចថ្មភ្នំ | ដីស | ខ្សាច់ភ្នំ | ផ្សេងៗ |
|---|---|---|---|---|---|---|---|---|---|
| ប្រភេទកម្រាល និងប្រវែងផ្លូវជនបទ (គ.ម) | | 15.100 | | 44.709 | 839.438 | | 260.166 | | |

## តារាងលទ្ធផលសារពើភ័ណ្ឌផ្លូវជនបទ ២០១០-២០២០ ខេត្តស្ទឹងត្រែង

| | | ខ្សែ | គ.ម | % អនុវត្ត |
|---|---|---|---|---|
| | ផែនការសរុប ២០១០-២០២០ | 170 | 1,159.413 | |
| | ដើមគ្រា | 53 | 560.339 | |
| ផែនការ និងការអនុវត្ត (២០១៥-២០២០) | ផែនការ | 117 | 599.074 | |
| | ក្នុងគ្រា | 117 | 599.074 | 100% |
| | បូកយោងអនុវត្តសរុប | 170 | 1,159.413 | 100% |

# ផែនទីផ្លូវជនបទខេត្តស្ទឹងត្រែង



# ១៩០១-ស្រុកសេសាន

# តារាងលទ្ធផលសារពើភ័ណ្ឌផ្លូវជនបទ ២០១០-២០២០ ស្រុកសេសាន

| ល.រ | លេខយោង | ឃុំ/សង្កាត់ | ឈ្មោះផ្លូវ | ប្រវែង(ម) | ទទឹង (ម) | និយាមកា ចំណុចដើមផ្លូវ x | y | ចំណុចចុងផ្លូវ x | y | ប្រភេទកម្រាល | ប្រភេទ | ប្រភពថវិកា | អនុវត្តដោយ | ឆ្នាំជួសជុល | សំណង់សិល្បការ្យ លូ | ស្ពាន |
|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|
| 1 | 023 | កំភុន | No78-ភូមិកាតួត | 3,300 | 3 | 622572 | 1486778 | 621707 | 1489636 | ដីស | 3 | | | | 0 | 0 |
| 2 | 039 | សាមឃួយ | ទួលសុវត្ថិភាព សាមឃួយ | 2,600 | 5 | 612318 | 1497168 | 612015 | 1494737 | ក្រួសក្រហម | 4 | ថវិកាជាតិ | មន្ទីរអភិវឌ្ឍន៍ជនបទ | 2011 | 4 | 0 |
| 3 | 047 | កំភុន | ភូមិកាតួត-ភូមិកំភុន | 11,400 | 5 | 622350 | 1489237 | 618454 | 1498318 | ល្បាយក្រួសអាចម៍ផ្កាយ | 1 | មូលនិធិឃុំ | ក្រុមប្រឹក្សាឃុំ | 2016 | 13 | 1 |
| 4 | 054 | ស្ដៅ | ផ្លូវជាតិលេខ៧-ភូមិស្ដៅ១ | 3,000 | 5 | 616122 | 1505700 | 618669 | 1504633 | ល្បាយក្រួសអាចម៍ផ្កាយ | 3 | ថវិកាជាតិ | ក្រុង | 2012 | 5 | 0 |
| 5 | 055 | ស្ដៅ | ផ្លូវជាតិលេខ៧-ភូមិស្ដៅ២ | 3,600 | 5 | 615784 | 1507341 | 618001 | 1504928 | ល្បាយក្រួសអាចម៍ផ្កាយ | 3 | ថវិកាជាតិ | ក្រុង | 2012 | 1 | 1 |
| 6 | 064 | ស្ដៅ | ផ្លូវជាតិលេខ៧-ចំនុចអ៊ីប៊ុ | 18,400 | 3 | 620552 | 1519752 | 635594 | 1524147 | ដីស | 2 | | | | 0 | 2 |
| 7 | 066 | កំភុន | ផ្លូវក្នុងភូមិកំភុន ខ្សែទី១ | 298 | 5 | 618131 | 1498681 | 618252 | 1498411 | ល្បាយក្រួសអាចម៍ផ្កាយ | 4 | មូលនិធិឃុំ | ក្រុមប្រឹក្សាឃុំ | 2011 | 2 | 0 |
| 8 | 067 | កំភុន | ផ្លូវក្នុងភូមិកំភុន ខ្សែទី២ | 1,100 | 5 | 618658 | 1498983 | 618039 | 1498372 | ល្បាយក្រួសអាចម៍ផ្កាយ | 4 | មូលនិធិឃុំ | ក្រុមប្រឹក្សាឃុំ | 2010 | 1 | 1 |
| 9 | 068 | កំភុន | ផ្លូវភូមិបានម៉ៃ-ភូមិកំភុន | 2,000 | 5 | 616968 | 1497823 | 618686 | 1498592 | ល្បាយក្រួសអាចម៍ផ្កាយ | 4 | មូលនិធិឃុំ | ក្រុមប្រឹក្សាឃុំ | 2011 | 2 | 0 |
| 10 | 073 | សាមឃួយ | ផ្លូវភូមិបាដើម | 2,200 | 5 | 615079 | 1496388 | 614549 | 1494265 | ល្បាយក្រួសអាចម៍ផ្កាយ | 4 | មូលនិធិឃុំ | ក្រុមប្រឹក្សាឃុំ | 2013 | 2 | 0 |
| 11 | 079 | ភ្លុក | ផ្លូវភូមិប៉ានប៉ុង | 3,000 | 4 | 622874 | 1499077 | 624621 | 1496902 | ល្បាយក្រួសអាចម៍ផ្កាយ | 4 | មូលនិធិឃុំ | ក្រុមប្រឹក្សាឃុំ | 2011 | 5 | 0 |
| 12 | 080 | ភ្លុក | ផ្លូវភូមិភ្លុក | 4,900 | 4 | 626451 | 1499879 | 625003 | 1496527 | ល្បាយក្រួសអាចម៍ផ្កាយ | 2 | មូលនិធិឃុំ | ក្រុមប្រឹក្សាឃុំ | 2012 | 8 | 2 |
| 13 | 087 | ស្ដៅ | ភូមិស្ដៅ១-ភូមិស្ដៅ២ | 4,700 | 4 | 620487 | 1504822 | 617316 | 1502027 | ល្បាយក្រួសអាចម៍ផ្កាយ | 4 | មូលនិធិឃុំ | ក្រុមប្រឹក្សាឃុំ | 2010 | 3 | 3 |
| 14 | 090 | ក្បាលរមាស | ផ្លូវភូមិស្រែស្រណុកខ្សែទី១ | 497 | 6 | 646040 | 1482073 | 646486 | 1481963 | ក្រួសក្រហម | 4 | ក្រុមហ៊ុនវារីអគ្គិសនីសេសានក្រោម២ | ក្រុមហ៊ុនវារីអគ្គិសនីសេសានក្រោម២ | 2015 | 0 | 0 |
| 15 | 091 | ក្បាលរមាស | ផ្លូវភូមិស្រែស្រណុកខ្សែទី២ | 445 | 6 | 646218 | 1482007 | 646303 | 1482436 | ក្រួសក្រហម | 4 | ក្រុមហ៊ុនវារីអគ្គិសនីសេសានក្រោម២ | ក្រុមហ៊ុនវារីអគ្គិសនីសេសានក្រោម២ | 2015 | 3 | 0 |
| 16 | 092 | ក្បាលរមាស | ផ្លូវភូមិស្រែស្រណុកខ្សែទី៣ | 278 | 6 | 646303 | 1482436 | 646568 | 1482415 | ក្រួសក្រហម | 4 | ក្រុមហ៊ុនវារីអគ្គិសនីសេសានក្រោម២ | ក្រុមហ៊ុនវារីអគ្គិសនីសេសានក្រោម២ | 2015 | 1 | 0 |

| ល.រ | លេខយោង | ឃុំ/សង្កាត់ | ឈ្មោះផ្លូវ | ប្រវែង(ម) | ទទឹង (ម) | និយាមកា ចំណុចដើមផ្លូវ x | y | ចំណុចចុងផ្លូវ x | y | ប្រភេទកម្រាល | ប្រឡាយ | ប្រភពថវិកា | អនុវត្តដោយ | ឆ្នាំជួសជុល | សំណង់សិល្បការ្យ លូ | ស្ពាន |
|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|
| 17 | 093 | ក្បាលរមាស | ផ្លូវភូមិស្រែស្រណុកខ្សែទី៤ | 498 | 6 | 646572 | 1482415 | 646480 | 1481936 | ក្រួសក្រហម | 4 | ក្រុមហ៊ុនវារីអគ្គិសនីសេសានក្រោម២ | ក្រុមហ៊ុនវារីអគ្គិសនីសេសានក្រោម២ | 2015 | 0 | 0 |
| 18 | 094 | ក្បាលរមាស | ផ្លូវភូមិស្រែស្រណុកខ្សែទី៥ | 3,700 | 6 | 646351 | 1481969 | 646557 | 1485571 | ក្រួសក្រហម | 4 | ក្រុមហ៊ុនវារីអគ្គិសនីសេសានក្រោម២ | ក្រុមហ៊ុនវារីអគ្គិសនីសេសានក្រោម២ | 2015 | 8 | 0 |
| 19 | 095 | ក្បាលរមាស | ផ្លូវភូមិស្រែស្រណុកខ្សែទី៦ | 933 | 6 | 646289 | 1482260 | 646959 | 1481828 | ក្រួសក្រហម | 4 | ក្រុមហ៊ុនវារីអគ្គិសនីសេសានក្រោម២ | ក្រុមហ៊ុនវារីអគ្គិសនីសេសានក្រោម២ | 2015 | 2 | 1 |
| 20 | 096 | ស្ដៅ | ផ្លូវភូមិស្ដៅ-ភូមិហាងសាវ៉ាត | 10,500 | 4 | 618249 | 1502878 | 612426 | 1497968 | ល្បាយក្រួសអាចម៍ផ្កាយ | 2 | មូលនិធិឃុំ | ក្រុមប្រឹក្សាឃុំ | 2011 | 3 | 3 |
| 21 | 097 | ស្ដៅ | ផ្លូវភូមិអ៊ីប៊ុ | 4,300 | 4 | 628069 | 1522461 | 631079 | 1519894 | ដីស | 4 | មូលនិធិឃុំ | ក្រុមប្រឹក្សាឃុំ | 2012 | 0 | 3 |
| 22 | 110 | ក្បាលរមាស | ផ្លូវភូមិក្បាលរមាសថ្មីខ្សែទី១ | 3,800 | 4 | 664395 | 1479259 | 665136 | 1481890 | ល្បាយក្រួសអាចម៍ផ្កាយ | 4 | ក្រុមហ៊ុនវារីអគ្គិសនីសេសានក្រោម២ | ក្រុមហ៊ុនវារីអគ្គិសនីសេសានក្រោម២ | 2016 | 0 | 3 |
| 23 | 111 | ក្បាលរមាស | ផ្លូវភូមិក្បាលរមាសថ្មីខ្សែទី២ | 329 | 4 | 664666 | 1479349 | 664544 | 1479652 | ល្បាយក្រួសអាចម៍ផ្កាយ | 4 | ក្រុមហ៊ុនវារីអគ្គិសនីសេសានក្រោម២ | ក្រុមហ៊ុនវារីអគ្គិសនីសេសានក្រោម២ | 2016 | 0 | 0 |
| 24 | 112 | ក្បាលរមាស | ផ្លូវភូមិក្បាលរមាសថ្មីខ្សែទី៣ | 335 | 4 | 665107 | 1479525 | 664984 | 1479832 | ល្បាយក្រួសអាចម៍ផ្កាយ | 4 | ក្រុមហ៊ុនវារីអគ្គិសនីសេសានក្រោម២ | ក្រុមហ៊ុនវារីអគ្គិសនីសេសានក្រោម២ | 2016 | 2 | 0 |
| 25 | 113 | ក្បាលរមាស | ផ្លូវភូមិក្បាលរមាសថ្មីខ្សែទី៤ | 948 | 4 | 665243 | 1479677 | 664365 | 1479321 | ល្បាយក្រួសអាចម៍ផ្កាយ | 4 | ក្រុមហ៊ុនវារីអគ្គិសនីសេសានក្រោម២ | ក្រុមហ៊ុនវារីអគ្គិសនីសេសានក្រោម២ | 2016 | 1 | 0 |
| 26 | 114 | ក្បាលរមាស | ផ្លូវភូមិក្បាលរមាសថ្មីខ្សែទី៥ | 970 | 4 | 664314 | 1479430 | 665213 | 1479789 | ល្បាយក្រួសអាចម៍ផ្កាយ | 4 | ក្រុមហ៊ុនវារីអគ្គិសនីសេសានក្រោម២ | ក្រុមហ៊ុនវារីអគ្គិសនីសេសានក្រោម២ | 2016 | 1 | 0 |
| 27 | 120 | ស្រែគរ | វារីអគ្គិសនី-ស្រែគរថ្មី | 26,600 | 5 | 635638 | 1496872 | 649965 | 1510392 | ល្បាយក្រួសអាចម៍ផ្កាយ | 2 | ក្រុមហ៊ុនវារីអគ្គិសនី | សំណាងពីក្រុមហ៊ុនវារីអគ្គិសនី | 2016 | 0 | 0 |

| ល.រ | លេខយោង | ឃុំ/សង្កាត់ | ឈ្មោះផ្លូវ | ប្រវែង(ម) | ទទឹង (ម) | និយាមកា ចំណុចដើមផ្លូវ x | y | ចំណុចចុងផ្លូវ x | y | ប្រភេទកម្រាល | ប្រភេទ | ប្រភពថវិកា | អនុវត្តដោយ | ឆ្នាំជួសជុល | សំណង់សិល្បការ្យ លូ | ស្ពាន |
|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|
| 28 | 122 | ស្រែគរ | ផ្លូវក្នុងភូមិស្រែគរថ្មីខ្សែទី១ | 540 | 5 | 642037 | 1508297 | 642046 | 1507768 | ល្បាយក្រួសអាចម៍ផ្កាយ | 4 | ក្រុមហ៊ុនសំណងវារីអគ្គិសនីសេសានក្រោម២ | ក្រុមហ៊ុនសំណងវារីអគ្គិសនីសេសានក្រោម២ | 2016 | 3 | 0 |
| 29 | 123 | ស្រែគរ | ផ្លូវក្នុងភូមិស្រែគរថ្មីខ្សែទី២ | 733 | 5 | 641541 | 1507751 | 642263 | 1507767 | ល្បាយក្រួសអាចម៍ផ្កាយ | 4 | ក្រុមហ៊ុនសំណងវារីអគ្គិសនីសេសានក្រោម២ | ក្រុមហ៊ុនសំណងវារីអគ្គិសនីសេសានក្រោម២ | 2016 | 0 | 0 |
| 30 | 124 | ស្រែគរ | ផ្លូវក្នុងភូមិស្រែគរថ្មីខ្សែទី៣ | 665 | 4 | 642268 | 1507647 | 642255 | 1508307 | ល្បាយក្រួសអាចម៍ផ្កាយ | 4 | ក្រុមហ៊ុនសំណងវារីអគ្គិសនីសេសានក្រោម២ | ក្រុមហ៊ុនសំណងវារីអគ្គិសនីសេសានក្រោម២ | 2016 | 2 | 0 |
| 31 | 125 | ស្រែគរ | ផ្លូវក្នុងភូមិស្រែគរថ្មីខ្សែទី៤ | 638 | 5 | 641831 | 1508126 | 642469 | 1508137 | ល្បាយក្រួសអាចម៍ផ្កាយ | 4 | ក្រុមហ៊ុនសំណងវារីអគ្គិសនីសេសានក្រោម២ | ក្រុមហ៊ុនសំណងវារីអគ្គិសនីសេសានក្រោម២ | 2016 | 0 | 0 |
| 32 | 126 | ស្រែគរ | ផ្លូវក្នុងភូមិស្រែគរថ្មីខ្សែទី៥ | 1,500 | 5 | 642043 | 1508000 | 643502 | 1508037 | ល្បាយក្រួសអាចម៍ផ្កាយ | 4 | ក្រុមហ៊ុនសំណងវារីអគ្គិសនីសេសានក្រោម២ | ក្រុមហ៊ុនសំណងវារីអគ្គិសនីសេសានក្រោម២ | 2016 | 2 | 0 |
| 33 | 127 | ស្រែគរ | ផ្លូវក្នុងភូមិស្រែគរថ្មីខ្សែទី៦ | 275 | 5 | 643504 | 1508160 | 643229 | 1508157 | ល្បាយក្រួសអាចម៍ផ្កាយ | 4 | ក្រុមហ៊ុនសំណងវារីអគ្គិសនីសេសានក្រោម២ | ក្រុមហ៊ុនសំណងវារីអគ្គិសនីសេសានក្រោម២ | 2016 | 0 | 0 |
| 34 | 128 | ស្រែគរ | ផ្លូវក្នុងភូមិស្រែគរថ្មីខ្សែទី៧ | 661 | 5 | 643232 | 1507669 | 643221 | 1508323 | ល្បាយក្រួសអាចម៍ផ្កាយ | 4 | ក្រុមហ៊ុនសំណងវារីអគ្គិសនីសេសានក្រោម២ | ក្រុមហ៊ុនសំណងវារីអគ្គិសនីសេសានក្រោម២ | 2016 | 1 | 0 |
| 35 | 132 | សាមឃួយ | ផ្លូវក្នុងភូមិសាមឃួយ | 1,000 | 5 | 610958 | 1496821 | 611927 | 1496972 | ដីស | 4 | | | | 0 | 0 |
| 36 | 155 | ស្រែគរ | ផ្លូវក្នុងភូមិស្រែគរថ្មីខ្សែទី៨ | 11,400 | 5 | 643366 | 1505313 | 649036 | 1506816 | ល្បាយក្រួសអាចម៍ផ្កាយ | 2 | ក្រុមហ៊ុនវារីអគ្គិសនី | សំណងពីក្រុមហ៊ុនវារីអគ្គិសនី | 2017 | 0 | 19 |

